# 8th ASEAN CENTRAL BANK GOVERNORS' MEETING

## Phnom Penh, Cambodia, 29th March 2012

*(to be delivered by Troika Governors at the 16th AFMM on 30th March 2012)*

Thank you Chair,

Honourable ASEAN Finance Ministers,

Honourable Central Bank Governors,

Distinguished Delegates, Ladies and Gentlemen,

1. We, the ASEAN Central Bank Governors' Troika (Indonesia, Cambodia and Brunei Darussalam), would like to share the results of the 8th ASEAN Central Bank Governors Meeting, which was held and concluded yesterday.

2. Four main areas were discussed in the meeting, namely, (1): Global and regional economic development and challenges for central banks after the global financial crisis; (2): Implementation of the ASEAN Financial Integration Framework (AFIF); (3): Publication of the summary report entitled "The Road to ASEAN Financial Integration"; and (4): Progress of the ASEAN+3 finance cooperation.

3. Now, on behalf of the ASEAN Central Bank Governors, let me briefly elaborate on each of these four important areas:

## I. Global and Regional Economic Development and Challenges for Central Banks after the Global Financial Crisis

4. Governors noted the IMF's views that global economic prospects have improved in 2012. After a sharp slowdown at the end of 2011, there is growing evidence that global activity is set to strengthen in the second half of 2012, as financial conditions eased after policymakers averted an imminent crisis in the Euro area. Nevertheless, large downside risks can stem from any less-than-steadfast resolution of the debt crisis in the Euro area and higher energy prices from increased geopolitical risks.

5. Governors also took note that economic growth in Asia is expected to gain momentum over the course of 2012. Domestic demand has generally remained strong, supported by low unemployment, high capacity utilization, and robust credit growth, thus buffering the impact of the weakening external demand. In the first months of 2012, leading indicators of activity strengthened, while inflation expectations have also picked up. As capital inflows have rebounded, increased vigilance on their potential volatility is therefore critical.

6. Governors recognized the difficult task faced by Asian policymakers in pursuing economic rebalancing and strengthening domestic sources of growth. At the same time, policy normalization may be needed to address any potential overheating pressures. Governors acknowledged that the balance of risks and the need for switching gears differ from country to country.

## II. ASEAN Monetary and Financial Integration

7. Governors appreciated the substantial progress made by the ASEAN Senior Level Committee on Financial Integration (SLC) since its

establishment in April last year. In particular, the SLC has mapped out an implementation plan for the key milestones and timelines under the ASEAN Financial Integration Framework (AFIF).

8. To further advance regional integration of the banking sector, the Governors supported the establishment of the Taskforce on ASEAN Banking Integration Framework (TF-ABIF) by the SLC. The Taskforce has already started work by taking stock of members' current state with respect to necessary preconditions for a smooth banking integration process in ASEAN.

9. Governors welcomed the progress in the implementation of the work plans of the Working Committees on Capital Market Development, Capital Account Liberalization, Financial Services Liberalization, and Payment and Settlement Systems. Highlights of these progress include: the development of a study to streamline and improve cooperation frameworks across various regional capital market initiatives such as the ASEAN Capital Market Forum; development of a capital account liberalization framework, which will guide the member countries' process of capital account liberalization including the drafting of timelines and milestones consistent with national agendas; the launch of the Sixth Round of negotiations on financial services liberalization under the ASEAN Framework Agreement on Services; and the finalization of action plans with due consideration of alignment with other working committees to ensure the smooth implementation of milestones and timelines for the harmonization of ASEAN payment and settlement system.

10. Governors acknowledged the importance of the SLC's establishment of the Steering Committee on Capacity Building Initiatives (SCCB), which is co-chaired by the Asian Development Bank and the SEACEN Research and Training Centre. Demand for and supply of capacity building have been identified by the Working Committees/Taskforce and coordinated by the SCCB to support ASEAN financial integration.

## III. Publication of Summary Report: "The Road to ASEAN Financial Integration"

11. Governors endorsed the publication of the report entitled "The Road to ASEAN Financial Integration", which provides a concise assessment of the financial landscape and propose a process towards greater financial integration in ASEAN in support of the goals of the ASEAN Economic Community.

## IV. ASEAN+3 Finance Cooperation

12. Governors took note of the progress under the ASEAN+3 finance cooperation process, particularly the enhancement of the Chiang Mai Initiative Multilateralization and the strengthening of the ASEAN+3 Macroeconomic Research Office's institutional and surveillance capacities.

13. Governors also look forward to participating for the first time in the ASEAN+3 Finance Ministers' Meeting in Manila in May this year.

# សុន្ទរកថាស្វាគមន៍

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៦

## ថ្លែងនៅក្នុង

## ពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៦

**រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២**

***- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

***- សហសេវិក រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន***

***- អគ្គទេសាភិបាលធនាគារកណ្តាល Troika ឥណ្ឌូនេស៊ី កម្ពុជា និង ប្រ៊ុយណេ***

***- អគ្គលេខាធិការអាស៊ាន***

***- តំណាងនៃធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ***

***- ប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន!***

១- ជាបឋម ក្នុងនាមរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅនិងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចូលរួមក្នុងការបើកកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៦នេះ។

២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដែលជាផ្នែកមួយនៃការដែលកម្ពុជាធ្វើជាប្រធានអាស៊ាន នៅឆ្នាំ២០១២នេះ មានសេចក្តីរីករាយនិងកិត្តិយសយ៉ាងជ្រាលជ្រៅ ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន និង កិច្ចប្រជុំពាក់ព័ន្ធ នាឱកាសនេះ ។ យើងខ្ញុំទាំងអស់គ្នា ជារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានជួបជុំគ្នាក្នុងថ្ងៃនេះ ដើម្បីផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក ព្រមទាំងពិនិត្យមើលឡើងវិញពីវឌ្ឍនភាពនៅក្នុងកិច្ចសហប្រតិបត្តិការ

ហិរញ្ញវត្ថុរបស់យើង ក្នុងគោលដៅស្វែងរកចំណាត់ការចាំបាច់នានា ដើម្បីរក្សាចលនការនៃកំណើនសេដ្ឋកិច្ច និងធានាស្ថេរភាពហិរញ្ញវត្ថុនៅក្នុងតំបន់ ។ យើងខ្ញុំក៏នឹងពិភាក្សាផងដែរអំពីការកៀរគរធនធានបន្ថែមទៀត ដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពផ្សេងៗនៃសហប្រតិបត្តិការ និង សមាហរណកម្មហិរញ្ញវត្ថុរបស់យើង ជាពិសេសដើម្បីរួមចំណែកដល់ការសម្រេចបាន**សហគមន៍សេដ្ឋកិច្ចអាស៊ាន** ឆ្នាំ ២០១៥ ។ ដូចនេះ កិច្ចប្រជុំឆ្នាំនេះនឹងពិភាក្សាលើប្រធានបទធំៗ ៦ គឺ: ***១)- ទស្សនវិស័យ និងការវិវត្តន៍សេដ្ឋកិច្ចតំបន់ ២)- កិច្ចដំណើរការពិនិត្យតាមដានសេដ្ឋកិច្ចអាស៊ាន ៣)- ផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មរូបិយវត្ថុនិងហិរញ្ញវត្ថុអាស៊ាន ៤)- កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ៥)- កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូកបី និង ៦)- បញ្ហាផ្សេងៗ*** ។

***- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

៣- ទោះបី សេដ្ឋកិច្ចសាកលលោកបាននិងកំពុងជួបប្រទះបញ្ហាជារចនាសម្ព័ន្ធ និង ភាពមិនប្រាកដប្រជាកម្រិតខ្ពស់ ខ្ញុំរីករាយនឹងរាយការណ៍ជូនសម្តេចតេជោនាយករដ្ឋមន្ត្រីជ្រាបថា សេដ្ឋកិច្ចតំបន់អាស៊ានយើងបានកើនឡើង ៤,៣ % កាលពីឆ្នាំ២០១១ កន្លងទៅ ។ កំណើនសេដ្ឋកិច្ចវិជ្ជមានប៉ុន្តែមានកម្រិតមធ្យមបែបនេះ កើតឡើងដោយសារតម្រូវការក្នុងស្រុកមិនស្រុតចុះ មូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចរឹងមាំ តារាងតុល្យភាពនៃវិស័យធនាគារ និង សាជីវកម្មមានលក្ខណៈរឹងប៉ឹង គួបផ្សំនឹងកំណែទម្រង់រចនាសម្ព័ន្ធដែលយើងបានធ្វើចាប់តាំងពីឆ្នាំ ១៩៩៧ មក ។ យើងជឿជាក់ថា សេដ្ឋកិច្ចរបស់យើងនឹងបន្តរីកលូតលាស់ឡើង ប្រកបដោយសុខភាព ក្នុងឆ្នាំ ២០១២នេះ ដែលកំណើន ផ.ស.ស ព្យាករណ៍ថានឹងកើនឡើងក្នុងរវាងពី ៥,៣ % ទៅ ៥,៨ % ។ អាស្រ័យហេតុនេះ កិច្ចប្រជុំថ្ងៃនេះ នឹងស្វះស្វែងរកគោលនយោបាយឆ្លើយតបដោយការសម្របសម្រួលដើម្បីរក្សាចីរភាព និង ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចចំពោះមុខហានិភ័យនានា ដូចជា ការធ្លាក់ចុះតម្រូវការពីក្រៅតំបន់ សភាពការណ៍ហិរញ្ញវត្ថុពិភពលោកតឹងតែង ថ្លៃប្រេងខ្ពស់ និងលំហូរមូលធនមិនទៀងទាត់ ។

***សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

៤- រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន បានជំរុញវឌ្ឍនភាពសំខាន់ៗជាច្រើន ក្នុងការងារសមាហរណកម្មទីផ្សារយើងឱ្យកាន់តែស៊ីជម្រៅ ស្របតាមផែនទីចង្អុលផ្លូវសម្រាប់សមាហរណកម្មរូបិយវត្ថុ និង ហិរញ្ញវត្ថុអាស៊ានក្នុងនោះ រួមមានការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ និង សេរីភាវូបនីយកម្មគណនីមូលធននិងសេវាហិរញ្ញវត្ថុ ។ ឧទាហរណ៍នៃវឌ្ឍនភាពទាំងនោះ មានដូចជា តារាងពិន្ទុសម្រាប់ការអភិវឌ្ឍផ្សារសញ្ញាប័ណ្ណអាស៊ាន ការបញ្ចប់កិច្ចចរចាលើកទី៥ និង ការចាប់ផ្តើមការចរចាលើកទី៦អំពីសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និង ការតភ្ជាប់ទីផ្សារទុនអាស៊ានដែលប្រទេសថៃ សិង្ហបុរី និងម៉ាឡេស៊ីបានភ្ជាប់គ្នារួចហើយ ។

៥- នៅក្នុងវិស័យដទៃទៀតនៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ យើងបាននិងកំពុងរៀបចំក្នុងដំណាក់កាលចុងក្រោយនូវការដាក់ឱ្យដំណើរការមូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន និង ដាក់សម្ពោធគម្រោងដំបូងនៃកម្មវិធីធានាឥណទាន និង វិនិយោគ (CGIF) ។ យើងសម្រេចបានវឌ្ឍនភាពក្នុងការដាក់ចេញវិធានថ្មីៗ ដើម្បីពង្រឹងប្រសិទ្ធភាពនៃពហុភាគូបនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ។ នៅថ្ងៃនេះដែរ យើងនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពន្ធគយដែលបានកែសម្រួលថ្មី ។ ចុងក្រោយ និង សំខាន់ផងដែរ គឺយើងសម្រេចបានវឌ្ឍនភាពល្អ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម។

៦- ជាជំហានទៅមុខសម្រាប់អាស៊ាន យើងនឹងបន្តដាក់ចេញនូវវិធានការច្បាស់លាស់ ដើម្បីធ្វើឱ្យសមាហរណកម្មហិរញ្ញវត្ថុអាស៊ានកាន់តែស៊ីជម្រៅនិងពង្រឹងសហប្រតិបត្តិការ នៅក្នុងផ្នែកអភិវឌ្ឍន៍ទីផ្សារមូលធនសហប្រតិបត្តិការផ្នែកគយពន្ធដារ និងធានារ៉ាប់រង ព្រមទាំងលើកកម្ពស់ទ្រព្យធនអាស៊ាន ( ASEAN Equities) ជាទ្រព្យសកម្មថ្នាក់ខ្ពស់មួយ ស្របតាម **ផែនទីចង្អុលផ្លូវសម្រាប់សមាហរណកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុអាស៊ាន** ។

៧- នៅក្នុងក្របខណ្ឌរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានបូកបី យើងបន្តប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការរបស់យើងជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ ។ យើងនឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការពិនិត្យវឌ្ឍនភាព នៃពហុភាគូបនីយកម្មគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ី (ABMI) និង សំណើផែនទីចង្អុលផ្លូវថ្មី ដែលផ្អែកលើការវាយតម្លៃរបស់ ក្រុមការងារចំពោះកិច្ចការ ABMI ទាំងបួន ដែលបានបង្កើតឡើង ។ យើងនឹងប្តេជ្ញាបញ្ចប់ការងារបង្កើ មូលនិធិនៃពហុ-ភាគូបនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ទ្វេដងគឺ ពី ១២០ ពាន់លាន ទៅដល់ ២៤០ ពាន់លានដុល្លារអាមេរិក។ ជាចុងក្រោយយើងនឹងសាកល្បងស្វែងរកកិច្ចសហប្រតិបត្តិការផ្សេងទៀតក្នុងពេលអនាគត

នៅក្រោមក្របខណ្ឌអាស៊ានបូកបី ជាពិសេស ក្នុងផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ ហិរញ្ញប្បទានហេដ្ឋា-រចនាសម្ព័ន្ធ និង ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ដើម្បីទូទាត់ផ្នែកពាណិជ្ជកម្ម ។

*- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន!*

៨- ក្នុងឋានៈជាប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានឆ្នាំនេះ កម្ពុជាបានខិតខំប្រឹងប្រែងដើម្បីស្វែងរកវឌ្ឍនភាពបន្ថែមទៀត ឆ្ពោះទៅសម្រេចឱ្យបាននូវ**សហគមន៍សេដ្ឋកិច្ចអាស៊ាន** ឆ្នាំ ២០១៥ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងជួយជំរុញថែមទៀតដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់កម្ពុជា ។ គោលដៅរបស់យើង គឺកាច់ចង្កូតកិច្ចដំណើរការនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន សំដៅសម្រេចគោលដៅរួម គឺ សន្តិសុខ សុវត្ថិភាព ស្ថិរភាព វិបុលភាព និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដើម្បីកែលម្អជីវភាព និងសុខមាលភាពប្រជាជនយើង និងតំបន់អាស៊ានទាំងមូល ។

៩- ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណចំពោះសហសេវិកអាស៊ាននិងលេខាធិការដ្ឋានអាស៊ាន ដែលបានផ្តល់កិច្ចសហការនិងគាំទ្រចំពោះកម្ពុជា ក្នុងអំឡុងពេលយើងធ្វើជាប្រធានរៀបចំកិច្ចប្រជុំលើកនេះ ។ ខ្ញុំក៏សូមសម្តែងនូវការអរគុណផងដែរ ចំពោះសហសេវិកពីរាជរដ្ឋាភិបាល និង មន្ត្រីរាជរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រចំពោះកិច្ចប្រជុំថ្ងៃនេះ។

១០- ដើម្បីជាមគ្គុទ្ទេសន៍សម្រាប់បន្តការងាររបស់យើង យើងទាំងអស់គ្នាមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមចែករំលែកនូវបញ្ញាញាណ និងទស្សនវិស័យ ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី ១៦ នេះ ។

១១- ក្នុងនាមរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានទាំងអស់ ប្រតិភូទាំងអស់ ភ្ញៀវកិត្តិយសអាស៊ានទាំងអស់ និង ខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគោរពអញ្ជើញសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មេត្តាឡើងផ្តល់នូវសុន្ទរកថាបើកដ៏ខ្ពង់ខ្ពស់ ។

*សូមអរគុណ!*